00998530

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 07 / 2014
ម៉ោង (Time/Heure): 11:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

E311/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អនុស្សរណៈ- អង្គជំនុំជម្រះសាលាដំបូង**

សាធារណៈ / Public

ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៤

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** របៀបវារៈសម្រាប់សវនាការបឋមបន្ថែមក្នុងសំណុំរឿង ០០២/០២ (ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤)

*សេចក្ដីផ្ដើម*

១. នៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានកំណត់យកថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ និង ប្រសិនបើចាំបាច់ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ សម្រាប់រៀបចំសវនាការបឋមបន្ថែមក្នុងសំណុំរឿង ០០២/០២ (ឯកសារ E311)។ អង្គជំនុំជម្រះបានកំណត់របៀបវារៈដូចខាងក្រោមសម្រាប់យកមកធ្វើការពិភាក្សា៖ (i) ការបញ្ជាក់បន្ថែមលើបញ្ហាសំណងរដ្ឋប្បវេណី (ii) បញ្ហាអញ្ញត្រកម្ម និងការពិនិត្យទៅលើបញ្ហាច្បាប់នានា ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ និង (iii) ការកំណត់លំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដី និងការពិនិត្យបឋមលើសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញសក្ខីកម្ម។ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឱ្យភាគីផ្ដល់យោបល់លើរបៀបវារៈដែលបានស្នើឡើងនេះនៅត្រឹមថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៤។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋ-

ប្បវេណីបានផ្តល់មតិយោបល់របស់ខ្លួនបន្តបន្ទាប់គ្នានៅថ្ងៃទី ១៩ និងនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។ អង្គជំនុំជម្រះពុំបានទទួលមតិយោបល់ពីភាគីផ្សេងទៀតឡើយ។

២. បន្ថែមទៅលើដីកាកំណត់កាលបរិច្ឆេទសវនាការ នៅពេលនេះអង្គជំនុំជម្រះសាលាដំបូងចេញរបៀបវារៈលម្អិតសម្រាប់សវនាការបឋមបន្ថែម។ ដូចអង្គជំនុំជម្រះធ្លាប់បានកត់សម្គាល់នាពេលមុនរួចមកហើយ សវនាការបឋមបន្ថែមមានគោលបំណងបញ្ជាក់បំភ្លឺលើបញ្ហានានានៅមុនពេលចាប់ផ្តើមសំណុំរឿង ០០២/០២ ។ អង្គជំនុំជម្រះសូមរម្លឹកថា បញ្ហាអញ្ញត្រកម្មទូទៅត្រូវបានពិចារណារួចហើយនៅក្នុងពេលសវនាការបឋមក្នុងខែ មិថុនា ឆ្នាំ ២០១១ (សូមមើលឯកសារ E307/1)។ នៅក្នុងអំឡុងពេលនៃសវនាការបឋមបន្ថែមនេះ អង្គជំនុំជម្រះនឹងមិនស្តាប់ទឡ្ហីករណ៍ទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហានានាក្រៅពីបញ្ហាដែលបានបញ្ជាក់នៅក្នុងរបៀបវារៈនេះឡើយ។

៣. សវនាការបឋមបន្ថែមនេះនឹងធ្វើឡើងជាសាធារណៈ លើកលែងតែការពិភាក្សាអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសក្តានុពល ដែលតម្រូវឱ្យធ្វើឡើងជាអសាធារណៈ។ ប្រសិនបើភាគីយល់ឃើញថា ការពិភាក្សាណាមួយចាំបាច់ត្រូវធ្វើឡើងជាអសាធារណៈ ភាគីអាចលើកសំណើសុំដោយផ្ទាល់មាត់បាននៅក្នុងពេលសវនាការ។ សវនាការជាអសាធារណៈនឹងរៀបចំឡើងនៅចុងបញ្ចប់នៃសវនាការ។ នៅក្នុងពេលធ្វើសវនាការជាសាធារណៈ ភាគីត្រូវប្រើឈ្មោះរហស្សនាមបុគ្គលទាំងអស់ ដែលខ្លួនមានបំណងស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

<u>**របៀបវារៈសម្រាប់សវនាការបឋមបន្ថែម (ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤)**</u>

<u>**របៀបវារៈទី១៖**</u> **ការបញ្ជាក់បន្ថែមលើបញ្ហាសំណងរដ្ឋប្បវេណី**

៤. អង្គជំនុំជម្រះសាលាដំបូងបានទទួលបណ្តឹងទាមទារសំណងចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០១ (ឯកសារ E218/7/6)។ បណ្តឹងទាមទារនេះនឹងយកមកវិនិច្ឆ័យសម្រេចនៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០១ ប្រសិនបើរកឃើញមានពិរុទ្ធ។

៥. អនុលោមតាមវិធាន *៨០ស្ទួន*(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឱ្យផ្តល់ការបញ្ជាក់បឋមអំពីខ្លឹមសារនៃសំណង ដែលខ្លួនមាន

00998532

បំណងស្នើសុំនៅក្នុងបណ្តឹងចុងក្រោយទាមទារសំណងផ្លូវចិត្ត និងជាសមូហភាព និងនៅក្នុងសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុង (ដោយមានរយៈពេលមិនលើស ២០ នាទី) នៅមុនពេលអង្គជំនុំជម្រះអញ្ជើញភាគីដទៃទៀតឱ្យបង្ហាញមតិយោបល់របស់ពួកគេ (ដោយភាគីនីមួយៗមានរយៈពេលមិនលើស ១០ នាទី)។ ការបញ្ជាក់បឋមនេះត្រូវរួមបញ្ចូលក្របខណ្ឌពេលវេលាសម្រាប់សំណើសុំ និងវិធានការបន្ថែម ផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធនឹងសំណើសុំទាំងនេះ។

៦. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើវិសាលភាពនៃសំណុំរឿង ០០២/០២ កំពុងរង់ចាំសេចក្តីសម្រេចនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ហើយសេចក្តីសម្រេចលើបណ្តឹងសាទុក្ខនេះ អាចមានអានុភាពប៉ះពាល់ដល់ការបង្គាប់លើសំណងដែលបានស្នើសុំ។

**<u>របៀបវារៈទី២៖</u> បញ្ហាអញ្ញត្រកម្ម និងការពិនិត្យទៅលើបញ្ហាច្បាប់នានា ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២**

៧. ក្នុងពេលថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា ក្នុងចំណោមអញ្ញត្រកម្មដែលនៅសេសសល់នៅក្នុងសំណុំរឿង ០០២ មានអញ្ញត្រកម្មចំនួនពីរពាក់ព័ន្ធនឹងអាជ្ញាយុកាលចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់នៃការនិរទេស ដែលនឹងត្រូវយកមកដោះស្រាយនៅក្នុងសវនាការនេះ (ឯកសារ E306)។ អង្គជំនុំជម្រះសាលាដំបូង បានទទួលព័ត៌មានសង្ខេបគ្រប់គ្រាន់លើអញ្ញត្រកម្មទាំងនេះ ហើយអង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្តីសម្រេចជាលាយ-លក្ខណ៍អក្សរឱ្យបានឆាប់តាមដែលអាចធ្វើបាននាពេលខាងមុខ។

៨. អង្គជំនុំជម្រះបានបង្គាប់ឱ្យភាគីបញ្ជាក់ប្រាប់នៅត្រឹមថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤ អំពីបញ្ហាអង្គច្បាប់ណាខ្លះ ដែលពួកគេមានបំណងចង់លើកឡើងនៅក្នុងពេលធ្វើសវនាការបឋមបន្ថែមនេះ (ឯកសារ E305)។ មានតែក្រុមមេធាវីការពារក្តី ខៀវ សំផន ប៉ុណ្ណោះ ដែលបានប្រើប្រាស់ឱកាសនេះដើម្បីបញ្ជាក់អំពីបំណងរបស់ខ្លួន (ឯកសារ E305/11)។ អង្គជំនុំជម្រះយល់ឃើញថា លើកលែងតែការស្នើសុំការបញ្ជាក់បន្ថែមអំពីសញ្ញាណនៃសំណុំរឿង ០០២/០១ ដែលចាត់ទុកជា "មូលដ្ឋានទូទៅ" សម្រាប់ការជំនុំជម្រះនាពេលក្រោយៗទៀតនោះ បញ្ហា

00998533

ទាំងអស់ ក្រៅពីបញ្ហាមួយនេះដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី ខៀវ សំផន ត្រូវបានដោះស្រាយនៅក្នុងរបៀបវារៈផ្សេងទៀតរួចហើយ ឬ ពុំពាក់ព័ន្ធនឹងសវនាការបឋមបន្ថែមនេះឡើយ។ អង្គជំនុំជម្រះសូមរម្លឹកដល់ភាគីថា សំណុំរឿង ០០២ គឺជាសំណុំរឿងតែមួយដែលសម្រាប់ដំណើរការនីតិវិធីបន្តបន្ទាប់ ហើយភស្តុតាងទាំងឡាយដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ រួចហើយនោះ គឺជាភស្តុតាងមូលដ្ឋានសម្រាប់សំណុំរឿង ០០២/០២ (សូមមើល ឯកសារ E302/5 កថាខណ្ឌ ៧)។ អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តី ខៀវ សំផន នឹងមានរយៈពេលមិនលើស ២០ នាទី សម្រាប់ធ្វើសេចក្តីសន្និដ្ឋានលើបញ្ហានេះ ហើយភាគីនីមួយៗផ្សេងទៀតមានរយៈពេលមិនលើស ១០ នាទី សម្រាប់ធ្វើសេចក្តីសន្និដ្ឋានតប។

៩. អង្គជំនុំជម្រះក៏អញ្ជើញភាគីឱ្យបង្ហាញផងដែរថាតើនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលនេះ ពួកគេមានបំណងស្នើសុំឱ្យមានការផ្លាស់ប្តូរការកំណត់បទចោទ និងទម្រង់នៃការទទួលខុសត្រូវដែលបានដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ដែរ ឬទេ (ភាគីនីមួយៗមានរយៈពេលមិនលើស ១០ នាទី)។

**<u>របៀបវារៈទី៣៖</u> ការកំណត់លំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី និងការពិនិត្យបឋមលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសក្ខីកម្ម**

*ក. ការកំណត់លំដាប់លំដោយនៃការជំនុំជម្រះ*

១០. អង្គជំនុំជម្រះសាលាដំបូងមានបំណងចង់ដឹងអំពីលទ្ធភាពដែលភាគីអាចមានវត្តមានចូលរួមបាននៅក្នុងអំឡុងពេលដែលនៅសេសសល់ក្នុងឆ្នាំ ២០១៤ នេះ និងក្នុងពេលខាងមុខ ដើម្បីចាប់ផ្តើមសវនាការដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០២។ ក្រោយពេលបញ្ចប់សវនាការបឋមបន្ថែមភ្លាម អង្គជំនុំជម្រះនឹងយកព័ត៌មានទាំងនេះទៅពិចារណា ហើយក្នុងពេលរង់ចាំការសម្រេចលើបញ្ហាពាក់ព័ន្ធផ្សេងទៀតនោះ អង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទចាប់ផ្តើមសវនាការដេញដោលលើភស្តុតាងតែម្តង។ បន្ថែមទៅនឹងការសាកសួររបស់អង្គជំនុំជម្រះសាលាដំបូង ការិយាល័យរដ្ឋបាលក៏បានបញ្ជាក់ផងដែរថា ការិយាល័យរដ្ឋបាលបានត្រៀមខ្លួនរួចជាស្រេចអស់ហើយ សម្រាប់គាំទ្រលើកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ "នៅគ្រប់ពេលវេលា" ទាំងអស់។

១១. អង្គជំនុំជម្រះសាលាដំបូងនឹងអញ្ជើញភាគីឱ្យធ្វើសេចក្តីសន្និដ្ឋានអំពីលំដាប់លំដោយនៃការបង្ហាញភ័ស្តុតាង ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពឱ្យបានដល់កម្រិតអតិបរមា និងធ្វើឱ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តិទៅប្រកបដោយភាពស៊ីសង្វាក់គ្នា។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យបែងចែកសំណុំរឿង ០០២/០២ ជាប្រាំវគ្គ៖ តួនាទីរបស់ជនជាប់ចោទ មន្ទីរសន្តិសុខ ការប្រព្រឹត្តិលើក្រុមគោលដៅ ការដ្ឋានធ្វើការងារ និងការរៀបអាពាហ៍ពិពាហ៍(នៅទូទាំងប្រទេស) (ឯកសារ E305/6)។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យការជំនុំជម្រះប្រព្រឹត្តទៅតាមលំដាប់លំដោយដូចតទៅ៖ មន្ទីរ ស-២១ ការបោសសម្អាតផ្ទៃក្នុង តួនាទីរបស់ជនជាប់ចោទ/សាក្សីនៃសហាក្រិដ្ឋកម្មរួម សហករណ៍ត្រាំកក់/មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល ការប្រល័យពូជសាសន៍ជនជាតិវៀតណាម ការប្រល័យពូជសាសន៍ជនជាតិចាម ការដ្ឋានទំនប់ ១ មករា ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ការរៀបការដោយបង្ខំ ទិដ្ឋភាពទូទៅនៃសំណុំរឿង ០០២/០២ (ឯកសារ E305/6 និងឯកសារ E305/6.1)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យការជំនុំជម្រះប្រព្រឹត្តទៅតាមលំដាប់លំដោយដូចតទៅ៖ មន្ទីរ ស-២១ ការបោសសម្អាតផ្ទៃក្នុង តួនាទីរបស់ជនជាប់ចោទ/សាក្សីនៃសហាក្រិដ្ឋកម្មរួម សហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ការប្រព្រឹត្តិលើពុទ្ធសាសនិកជន ការប្រព្រឹត្តិលើជនជាតិវៀតណាម ការប្រព្រឹត្តិលើជនជាតិចាម ការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទីពីរដោយសារវាពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិចាម ការដ្ឋានទំនប់ ១ មករា ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខអូរកន្សែង ការរៀបចំអាពាហ៍ពិពាហ៍ និងអ្នកជំនាញ (ឯកសារ E305/7.1.4)។

១២. អង្គជំនុំជម្រះសាលាដំបូង នឹងអញ្ជើញក្រុមមេធាវីការពារក្តីឱ្យផ្តល់យោបល់លើលំដាប់លំដោយនៃការជំនុំជម្រះដែលបានស្នើសុំនេះ (ដែលមានរយៈពេលមិនលើស ១៥ នាទី សម្រាប់ក្រុមនីមួយៗ) មុនពេលអញ្ជើញសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឱ្យធ្វើការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី (ដែលមានរយៈពេលមិនលើស ១៥ នាទីសម្រាប់ក្រុមនីមួយៗ)។ អង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចលើលំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយ

នឹងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរមួយ ក្រោយពេលបញ្ចប់សវនាការបឋមបន្ថែមនេះ។

*ខ. បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ*

១៣. បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាលើបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសក្តានុពល ដែលភាគីបានដាក់ជូនសម្រាប់សំណុំរឿង ០០២/០២ យោងតាមដីការបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤ (ឯកសារ E305)។ ក្នុងចំណោមនោះ ភាគីបានស្នើសុំឱ្យបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨៨ នាក់ អ្នកជំនាញចំនួន ២០ នាក់ និងសាក្សីចំនួន ១២១ នាក់ ដែលសរុបទាំងអស់មានចំនួន ២២៩ នាក់ (ឯកសារ E305/4.2 ឯកសារ E305/5.2 ឯកសារ E305/6.1 និងឯកសារ E305/7.1.4)។ លើសពីនេះទៀត សហព្រះរាជអាជ្ញាបានស្នើសុំបន្ថែម “សាក្សីបម្រុង” ចំនួន ៣៥ នាក់ បន្ថែមទៀត (ឯកសារ E305/6.1)។ ក្រោយពីពិនិត្យមើលចំនួនបុគ្គលនៅក្នុងបញ្ជីទាំងនេះ ហើយនិងរយៈពេលដែលនឹងចំណាយសម្រាប់ស្តាប់សក្ខីកម្មបុគ្គលជាច្រើននាក់បែបនេះ អង្គជំនុំជម្រះនឹងអញ្ជើញឱ្យភាគីលើកឡើងអំពីការកាត់បន្ថយចំនួនបុគ្គល នៅក្នុងបញ្ជីរបស់ពួកគេ។ អង្គជំនុំជម្រះក៏នឹងអញ្ជើញឱ្យភាគីផ្តល់មតិយោបល់លើការជំទាស់នានាលើបញ្ជីទាំងនេះ ដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី ខៀវ សំផន (ឯកសារ E305/9) និងដោយសហព្រះរាជអាជ្ញាជាតិផងដែរ (ឯកសារ E305/10)។

១៤. ក្រុមមេធាវីការពារក្តី ខៀវ សំផន បានជំទាស់លើឈ្មោះបុគ្គលមួយចំនួន ដែលស្នើឡើងនៅក្នុងបញ្ជីឈ្មោះចុងក្រោយរបស់សហព្រះរាជអាជ្ញា ហើយបានតវ៉ាថា ពួកគេពុំមានព័ត៌មានគ្រប់គ្រាន់ពាក់ព័ន្ធនឹងបុគ្គលមួយចំនួន និងវិសាលភាពនៃការជំនុំជម្រះ សម្រាប់ឱ្យពួកគេយកមកវាយតម្លៃលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានស្នើសុំនោះឡើយ (ឯកសារ E305/9)។ អង្គជំនុំជម្រះសាលាដំបូងនឹងអញ្ជើញភាគីឱ្យធ្វើសេចក្តីសន្និដ្ឋានលើជំហររបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន មុនពេលប្រគល់វេទិកាឱ្យក្រុមមេធាវីការពារក្តី ខៀវ សំផន ធ្វើការឆ្លើយតប។

១៥. ពីដំបូង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បញ្ចូល TCCP-19 ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលសហមេធាវីនាំមុខបានស្នើសុំវិធានការការពារបុគ្គលរូបនេះនៅក្នុង

បញ្ជីឈ្មោះចុងក្រោយរបស់ពួកគេ (សូមមើល ឯកសារ E305/7.1.2)។ ទោះបីជាយ៉ាងនេះក្តី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ប្រាប់តាំងពីពេលនោះមកថា បុគ្គលរូបនេះលែងត្រូវការវិធានការការពារទៀតហើយ ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដកសំណើសុំវិធានការការពារសម្រាប់បុគ្គលនេះ (ឯកសារ E305/7/2) ។ អង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ឱកាសឲ្យភាគីផ្សេងទៀតជំទាស់នឹងការដាក់បញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

១៦. ភាគីនីមួយៗមានរយៈពេលយ៉ាងច្រើនបំផុត ៣០ នាទី សម្រាប់លើកជូនអង្គជំនុំជម្រះអំពីបញ្ហាទាំងឡាយខាងលើ ពាក់ព័ន្ធនឹងបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសក្ខីកម្ម។